# ការធ្វើបណ្តឹង

អ្នកមានសិទ្ធិទទួលបានការថែទាំសុខភាព ដែលមានសុវត្ថិភាព និងគុណភាព ហើយត្រូវបានគេព្យាបាលដោយការគោរព។ ការលើកឡើងនូវកង្វល់របស់អ្នក ពេលណាការនេះមិនកើតមានឡើង ការពារសិទ្ធិរបស់អ្នក ហើយអាចកែលម្អប្រព័ន្ធសុខភាពសម្រាប់គ្រប់ពលរដ្ឋវិចតូរីយ៉ា។



សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីបំពេញសំណុំបែបបទពាក្យបណ្តឹងតាមអនឡាញ សូមបើកចូលវិបសាយ **hcc.vic.gov.au**

ទូរស័ព្ទ **1300 582 113** រវាងម៉ោង៩ព្រឹក និងម៉ោង៥ល្ងាច ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ដើម្បីពិភាក្សាអំពីពាក្យបណ្តឹងរបស់អ្នក។

HEALTH COMPLAINTS COMMISSIONER



HEALTH COMPLAINTS COMMISSIONER

ការធ្វើបណ្តឹង

Khmer | ភាសាខ្មែរ

គាំទ្រការថែទាំសុខភាពដែលមានសុវត្ថិភាព និងត្រឹមត្រូវតាមសីលធម៌



# តើខ្ញុំអាចធ្វើបណ្ដឹងអំពីអ្វីខ្លះ?

បញ្ហាទាំងឡាយដែលអ្នកអាចធ្វើបណ្ដឹង រួមមាន:

- ការព្យាបាលមិនជាទីពេញចិត្ត
- មានបញ្ហាការទទួលចូល ឬការបញ្ជូន
- ការប្រាស្រ័យទាក់ទងមិនល្អ
- ខ្វះការគោរព ឬភាពឯកជន
- អាកប្បកិរិយាឆ្វេសប្រហែស ឬដែលគ្មានវិជ្ជាជីវៈ
- ចាត់ចែងព័ត៌មានសុខភាពដែលគ្មានប្រសិទ្ធិភាព។

អ្នកអាចធ្វើបណ្ដឹងអំពីស្ថាប័នផ្ដល់សេវាសុខភាពណាមួយ នៅក្នុងរដ្ឋវិចតូរីយ៉ា។ នេះមានរួមទាំងមន្ទីរពេទ្យរដ្ឋ ឬឯកជន សេវាសុខភាពសហគមន៍ ស្ថាប័នផ្ដល់សេវាដែលចុះបញ្ជីស្របច្បាប់ ដូចជាវេជ្ជបណ្ឌិត និងគ្រូពេទ្យធ្មេញ ឬស្ថាប័នផ្ដល់សេវាដែលមិនចុះបញ្ជីស្របច្បាប់ ដូចជាអ្នកផ្ដល់ប្រឹក្សា និងអ្នកព្យាបាលដោយជម្រើសផ្សេងទៀត។

អ្នកក៏អាចធ្វើបណ្ដឹងផងដែរ អំពីនរណាម្នាក់ដែលកាន់កាប់ព័ត៌មានសុខភាពរបស់អ្នក រួមមានស្ថាប័នផ្ដល់សេវាមិនមែនផ្នែកសុខភាព ដូចជាសាលារៀន និងកន្លែងហាត់ប្រាណ អំពីរបៀបដែលពួកគេចាត់ចែងព័ត៌មាននោះ។

# តើខ្ញុំធ្វើបណ្ដឹងដោយរបៀបណា?

ជំហានដំបូង គឺអនុញ្ញាតឱ្យស្ថាប័នផ្ដល់សេវារបស់អ្នកបានដឹងអំពីកង្វល់របស់អ្នក។ ប្រសិនបើពួកគេមិនអាចដោះស្រាយបញ្ហានេះទេ ឬអ្នកមានអារម្មណ៍ថា អ្នកមិនអាចនិយាយជាមួយពួកគេបាន សូមស្នើសុំជំនួយពីយើងខ្ញុំ។

អ្នកណាម្នាក់អាចដាក់ពាក្យបណ្ដឹងជាមួយយើងខ្ញុំ តាមអនឡាញ តាមទូរស័ព្ទ ឬដោយផ្ទាល់។ ប្រសិនបើអ្នកកំពុងប្ដឹងតវ៉ាសម្រាប់នរណាម្នាក់ផ្សេងទៀត អ្នកគួរតែទទួលការយល់ព្រមរបស់ពួកគេជាមុនសិន។

# តើមានអ្វីកើតឡើងបន្ទាប់មក?

យើងខ្ញុំធ្វើការជាមួយអ្នក និងស្ថាប័នផ្ដល់សេវាដើម្បីដោះស្រាយពាក្យបណ្ដឹងឱ្យបានឆាប់រហ័ស ដោយយុត្តិធម៌ និងមានប្រសិទ្ធិភាព។

យើងខ្ញុំអាចជួយអ្នកទទួលបាន:

- ការពន្យល់អំពីអ្វីដែលបានកើតឡើង
- ការសុំអភ័យទោស
- លទ្ធភាពទទួលការព្យាបាល
- លទ្ធភាពបើកមើលកំណត់ត្រា
- ប្រាក់សងមកវិញ ឬសំណង
- ការផ្លាស់ប្ដូរនៅក្នុងគោលនយោបាយ ឬការអនុវត្តន៍ដើម្បីការពារបញ្ហាកើតមាននៅពេលអនាគត។

យើងខ្ញុំក៏អាចចាប់ផ្ដើមធ្វើការស៊ើបអង្កេតជាផ្លូវការផងដែរ ហើយព្រមានសាធារណៈជន អំពីស្ថាប័នផ្ដល់សេវាសុខភាពដែលមានគ្រោះថ្នាក់។

សេវាកម្មរបស់យើងខ្ញុំផ្ដល់ជូនដោយឥតគិតថ្លៃ រក្សាការសម្ងាត់ ហើយមិនលំអៀង។

## ទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីបំពេញសំណុំបែបបទពាក្យបណ្ដឹងតាមអនឡាញ សូមបើកចូលវ៉ិបសាយ **hcc.vic.gov.au**

ទូរស័ព្ទ **1300 582 113** រវាងម៉ោង៩ព្រឹក និងម៉ោង៥ល្ងាច ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ដើម្បីពិភាក្សាអំពីពាក្យបណ្ដឹងរបស់អ្នក។

សូមអញ្ជើញមក ឬសរសេរមកយើងខ្ញុំនៅអាសយដ្ឋាន
Level 26, 570 Bourke Street, Melbourne Victoria 3000

តើថ្លង់ ពិបាកស្ដាប់ ឬអន់ខ្សោយក្នុងការនិយាយស្ដីឬ?
**relayservice.gov.au**

តើត្រូវការអ្នកបកប្រែភាសាឬទេ?
TIS National: **131 450**

នេះគឺជាព័ត៌មានដែលមានលក្ខណៈទូទៅ ហើយមិនមានបំណងជាការផ្ដល់ដំបូន្មានផ្នែកច្បាប់ឡើយ